

# The Community-Based Childcare Centers Project

## ENGLISH VERSION

The Community-Based Childcare Centers (CBCC) Project is a 4 years project starting in 2020 until 2024. Funded by Japan Social Development Fund (JSDF) managed by the World Bank for the account of the Government of Japan, the CBCC Project will be implemented by Planète Enfants & Développement (PE&D), a French NGO specializing in early childhood areas.

The Project intends to experiment new models to provide sustainable, affordable, safe and quality childcare services for very young children of garment factory workers, partly financed by their employers in accordance with the Cambodian Labor Law. The Project will help the garment factory workers to strive for a better balance between their private and professional lives, while improving child development. It will also allow family members who are traditionally taking care of young children to save time for other personal or economic activities.

In this view, **22 Childcare Centers will be built in communities, closed to garment factory workers and their families' homeplace.** These Community-Based Childcare Centers will provide a safe, healthy and stimulating environment to welcome very young children (06-36 months) during garment workdays, and ensuring their right physical, psychological and cognitive development. Centers will be managed by trained professional staff, under the supervision of PE&D Project Team. Centers will be economically sustainable, thanks to funding from garment factories which are partnering with the Project, and fees payed each month by the parents.

Whereas the Childcare services will be accessible only to employees of garment factories partnering with the Project, all community members will benefit from the establishment in their commune, as parenting education training and sensitization programs will be delivered in the CBCCs and fully accessible for all.

## Why implementing the CBCC project?

The CBCC project will aim at filling the gap for affordable and quality childcare services in Cambodia, especially in rural areas and for low-income workers.

In Cambodia, there are no public daycare services and very few functional factory daycare centers. Private daycare services are available and growing in urban areas but are not financially accessible for most garment factory workers. Garment factory workers frequently quit their jobs for lack of childcare support, electing to stay home with their children instead.

The Cambodian Labor Law (1997), Article 186, requires enterprises employing more than 100 women to either establish a daycare center on-premises for children 18-36 months of age, or to pay for employee's childcare costs elsewhere. However, most of the factories are non-compliant and there are almost no operating on-site daycares.

# CBCC design and construction. What will they imply for the communities and their environment?

Each CBCC will be built, following the same construction design and equipment prescriptions established by PE&D specialists and international consultants, in compliance with the standards set in the World Bank Environmental and Social Risk Framework, which sets out the World Bank's commitment to sustainable development, through a Bank Policy and a set of Environmental and Social Standards. .

In this view, the Project Documentation, in particular the *Construction Guidelines*, documents all the instructions to complete the construction process from scoping potential CBCC locations to opening the doors, including the rules which will apply for construction companies. The *Guidelines* define also how the CBCC constructions will apply the highest environmental, health, safety and social standards, Once the project starts, the *Construction Guidelines* are intended to be finalized and completed by the *CBCC Operational Guidelines*, which will define the day-to-day operations within CBCC and how daily environmental, social, safety and health risks will be mitigated, especially for the children's and CBCC staff's sake.

CBCC design will ensure the highest safety, health, stimulating and warming environment to welcome young children, with security provisions (security fences, smoke detector, safe place to store materials that might injure the children, locked doors) and health / hygiene equipment (fans in all rooms, unlimited drinkable water, proper sanitation, first aid kit). CBCC design will also provide dedicated areas for day-to-day children activities, such as activity rooms, nap rooms, outdoor playground.

Centers will be located on public land, with full of the agreement of the Commune Councils and Village Chiefs. Lands will be selected after a systematic Social & Environmental Assessment, to ensure that the location will be safe from any environmental risks or hazards (flooding, pollution, dangerous flora and fauna, dangerous neighboring activities, water pounds). The existence of cultural heritage or structures to be preserved, and the lack of UneXploded Ordnance or land users will also be systematically checked.

During the Construction, all project stakeholders will strictly follow an Environmental & Social Management Plan to ensure that all risks (workers and population safety, protection of the environment and cultural heritage) or nuisance (noise, dust) for the local environment and communities will be addressed and mitigation measures will be undertaken.

Once opened, the CBCCs will be equipped with septic tank to avoid any water discharge in the environment. CBCC locations will also be chosen to avoid any noise nuisance generated by children activities, as much as possible.

Due to the limited scale of each Centers, the impacts on the environment and communities should be limited.

# Community Consultation. How could you share your feedbacks?

Community engagement is key for the success of the project. The Project Team has already conducted several rounds of consultation with national and local authorities, and a panel of garment factory workers and their families.

Prior to any site selection, the Team Project will organize a consultation process in the communities to present the project, the design of the CBCC and welcome any feedbacks or concerns. This process will make sure that the CBCC design is adapted to the specific situation of this community and of its members.

During the whole construction stage, this Executive Summary (Khmer/English), the Construction Guidelines (English) and a register will be made available at the Commune Hall for anyone who would like to share comments about any aspects of the Project. Consultation sessions will be pursued, and on-site visits might be organized for the community members, once safety if guaranteed.

Besides, the Project Documentation, including PE&D Environmental & Social Commitment Plan for this project, will be disclosed in PE&D website : www.planete-eed.org/en

Once opened, the consultation process will continue. The Project Documentation will be available in each CBCC. A CBCC Advisory Committee will be established for each CBCC and will involve the village chief, the preschool teacher if any, elected/voluntary parents, the CBCC Manager, representatives of the Commune Committee for Women and Children (CCWC), district education and health officers, and representatives of factory management. PE&D project staff will support the facilitation of the meetings. Besides, once a year, a community meeting will be organized to conduct a Community Scorecard of the CBCC to assess the quality of services.

# About PE&D and The World Bank Group

**Planète Enfants & Développement (PE&D**) is a French NGO expert in Early Childhood Care and Développement. PE&D was created in 1984 as “SOS Children of Cambodia” in order to help the child victims of the war. Since, our team has been operating to provide early childhood development (0-6 years), family and parenting support, as well as maternal and infant health.

**The World Bank** is an international financial institution, established in 1944, to provide loans, grants, policy advice and technical support to developing countries. The World Bank is part of The World Bank Group which has set two goals for the World to achieve by 2030:

- End extreme poverty by decreasing the percentage of people living on less than $1.90 a day to no more than 3%
- Promote shared prosperity by fostering the income growth of the bottom 40% for every country



# គម្រោងការបង្កើតទារកដ្ឋានតាមសហគមន៍

## KHMER VERSION

គម្រោងទារកដ្ឋានប្រចាំសហគមន៍ (CBCC) គឺមានរយៈពេល ០៤ឆ្នាំ នឹងត្រូវបានចាប់ផ្តើមនៅឆ្នាំ ២០២០ រហូតដល់ ឆ្នាំ ២០២៤។ គម្រោងនេះផ្តល់ថិកាគាំទ្រដោយមូលនិធិអភិវឌ្ឍន៍សង្គមជប៉ុន (JSDF) និងគ្រប់គ្រងដោយធនាគារពិភពលោក សម្រាប់ទទួលខុសត្រូវជាមួយរដ្ឋាភិបាលជប៉ុន គម្រោងទារកដ្ឋានប្រចាំសហគមន៍នឹងត្រូវបានអនុវត្តន៍ដោយ អង្គការ ពិភពកុមារ និងអភិវឌ្ឍន៍ (PE&D) ដែលជាអ្នកជំនាញខាងការងារកុមារតូច។

គម្រោងមានគោលបំណងដើម្បីសាកល្បងគំរូថ្មីលើការផ្តល់នូវសេវាថែទាំកុមារប្រកបដោយនិរន្តរភាព តម្លៃសមរម្យ មានសុវត្ថិភាព និងគុណភាពសម្រាប់កុមារតូច ដែលត្រូវជាកូនរបស់កម្មកររោងចក្រកាត់ដេរ ហើយមួយផ្នែកនៃហិរញ្ញប្បទានត្រូវបានផ្តល់ដោយនិយោជករបស់ពួកគេដែលស្របទៅតាមច្បាប់ការងារនៅកម្ពុជា។ គម្រោងនេះនឹងជួយដល់កម្មកររោងចក្រកាត់ដេរ ដើម្បីឱ្យមានតុល្យភាពរវាងជីវិតឯកជន និងមុខរបររបស់ពួកគេ ក្នុងខណៈពេលដែលកំពុងផ្តល់ការអភិវឌ្ឍកុមារ។ គម្រោងនេះនឹងផ្តល់អោយសមាជិកគ្រួសារដែលមានទំលាប់ថែរទាំកុមារតូច អាចមានពេលវេលាសម្រាប់សកម្មភាពផ្ទាល់ខ្លួន ឬសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត។

នៅក្នុងគម្រោងនេះ ទារកដ្ឋានចំនួន ២២កន្លែង នឹងត្រូវសាងសង់ក្នុងសហគមន៍ដែលនៅជិតផ្ទះរបស់កម្មកររោងចក្រកាត់ដេរ និងគ្រួសាររបស់ពួកគេ។ ទារកដ្ឋានប្រចាំសហគមន៍នឹងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព សុខភាព និងរំញោចដើម្បីស្វាគមន៍កុមារតូចៗ (អាយុ០៦-៣៦ខែ) ក្នុងកំឡុងពេលថ្ងៃធ្វើការ និងធានាការអភិវឌ្ឍខាងរាងកាយ ផ្លូវចិត្ត និងការយល់ដឹងរបស់ពួកគេ។ ទារកដ្ឋាននឹងត្រូវគ្រប់គ្រងដោយបុគ្គលិកដែលមានជំនាញដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ក្រោមការត្រួតពិនិត្យពីក្រុមការងារគម្រោង PE&D ។

ទារកដ្ឋាននឹងមាននិរន្តរភាពផ្នែកសេដ្ឋកិច្ច ដោយសារនឹងមានការផ្តល់ថវិកាពីភាគីខាងរោងចក្រកាត់ដេរដែលបានចាប់ដៃគូជាមួយគម្រោង និងថ្លៃឈ្នួលដែលឪពុកម្តាយបានបង់ជារៀងរាល់ខែ។

ចំណែកឯសេវាទារកដ្ឋាននឹងអាចផ្តល់បានតែចំពោះនិយោជិកនៃរោងចក្រកាត់ដេរដែលចាប់ដៃគូជាមួយគម្រោងតែប៉ុណ្ណោះ សមាជិកសហគមន៍ទាំងអស់នឹងទទួលបានអត្ថប្រយោជន៍ពីការបង្កើតនៅក្នុងឃុំរបស់ពួកគេ ដែលមានដូចជា កម្មវិធីបណ្តុះបណ្តាលការអប់រំមាតាបិតា និងកម្មវិធីរំញោចអារម្មណ៍ដែលនឹងត្រូវបានផ្តល់ជូននៅក្នុង CBCCs និងអាចផ្តល់ជូនសម្រាប់អ្នកទាំងអស់គ្នា។

## ហេតុអ្វីបានជាអនុត្តន៍គម្រោងទារកដ្ឋានប្រចាំសហគមន៍?

CBCC នឹងមានគោលបំណងបំពេញគំលាតសម្រាប់ផ្តល់អោយមានតំលៃសមរម្យ និងមានគុណភាពសម្រាប់សេវាទារកដ្ឋាននៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅតាមទីជនបទ និងសម្រាប់កម្មករដែលមានប្រាក់ចំណូលទាប។

នៅប្រទេសកម្ពុជាពុំមានសេវាទារដ្ឋាននៅតាមទីសាធារណៈទេ ហើយទារកដ្ឋាននៅតាមរោងចក្រមានដំណើរការតិចតួចណាស់។ សេវាទារកដ្ឋានឯកជនអាចរកបាន និងរីកចម្រើននៅតាមតំបន់ទីក្រុងតែប៉ុណ្ណោះ ហើយកម្មកររោងចក្រកាត់ដេរភាគច្រើនមិនអាចមានថវិកាដើម្បីទៅរកសេវានេះបានទេ។ កម្មកររោងចក្រកាត់ដេរតែងតែឈប់ធ្វើការដោយសារហេតុផល ខ្វះអ្នកមើលថែកូន រួចជ្រើសរើសការនៅផ្ទះជាមួយកូនជំនួសវិញ។

ច្បាប់ការងារនៅកម្ពុជា (ឆ្នាំ ១៩៩៧) មាត្រា ១៨៦ តម្រូវឲ្យ សហគ្រាសដែលជួលស្ត្រីច្រើនជាង ១០០ នាក់ឱ្យបង្កើតទារកដ្ឋាននៅកន្លែងធ្វើការសម្រាប់ក្មេងអាយុ ១៨-៣៦ ខែ ឬបង់ថ្លៃថែទាំកុមាររបស់និយោជិកនៅកន្លែងផ្សេង។ ទោះជាយ៉ាងណារោងចក្រភាគច្រើនមិនគោរពតាមទេ ហើយស្ទើរតែមិនមានដំណើរការទារកដ្ឋាននៅនឹងកន្លែងផង។

## ការសាងសង និងរចនាប្លង់របស់ **CBCC** ។ តើពួកគេនឹងបញ្ជាក់អ្វីសម្រាប់សហគមន៍ និងបរិស្ថានរបស់ពួកគេ?

CBCC នីមួយៗនឹងត្រូវបានសាងសង់តាមរចនាប្លង់ និងគ្រឿងបរិក្ខារដូចៗគ្នា ដែលបានបង្កើតឡើងដោយអ្នកជំនាញ PE&D និងអ្នកពិគ្រោះយោបល់អន្តរជាតិ។

ការរចនាប្លង់ CBCC នឹងធានាបាននូវបរិយាកាសប្រកបដោយសុវត្ថិភាព រំញោច និងកក់ក្តៅខ្ពស់បំផុត ដើម្បីស្វាគមន៍កុមារតូចៗ ដោយមានបទប្បញ្ញត្តិសុវត្ថិភាពដែលមានដូចជា របងសុវត្ថិភាព ឧបករណ៍ស្រូបផ្សែង កន្លែងសុវត្ថិភាពក្នុងការផ្ទុកសំភារៈដែលអាចបង្ករបួសដល់កុមារ ទ្វារមានសោចាក់ត្រឹមត្រូវ និងឧបករណ៍ដែលមានសុខភាព / អនាម័យ (កង្ហារនៅគ្រប់បន្ទប់ទាំងអស់ មានទឹកញ៉ាំគ្រប់គ្រាន់ អនាម័យត្រឹមត្រូវ និងឧបករណ៍សង្គ្រោះបឋម) ។ ការរចនាប្លង់ CBCC នឹងមានកន្លែងសម្រាប់សកម្មភាពប្រចាំថ្ងៃរបស់កុមារផងដែរ ដូចជាបន្ទប់សម្រាប់ធ្វើសកម្មភាព បន្ទប់គេង និងកន្លែងលែងខាងក្រៅផងដែរ។

ទាករដ្ឋាននឹងសាងសងលើដីសាធារណៈរបស់រដ្ឋ ដោយមានការព្រមព្រៀងពីក្រុមប្រឹក្សាឃុំ និងមេឃុំ។ ដីនឹងត្រូវបានជ្រើសរើសបន្ទាប់ពីការវាយតំលៃសង្គម និងបរិស្ថានជាប្រព័ន្ធរួច ដើម្បីធានាថាទីតាំងនឹងមានសុវត្ថិភាពពីហានិភ័យ ឬគ្រោះថ្នាក់បរិស្ថាន ដែលមានដូចជា ទឹកជំនន់ ការបំពុលបរិស្ថាន គ្រោះថ្នាក់ដែលបង្ករដោយ រុក្ខជាតិ និងពពួកសត្វ និងគ្រោះថ្នាក់ដែលបង្ករដោយសកម្មភាពអ្នកជិតខាងផ្សេងៗ។ ការរស់នៅ ឬរចនាសម្ព័ន្ធតាមបែបបេតិកភណ្ឌវប្បធម៌ នឹងត្រូវបានអភិរក្ស និងកង្វះខាតគ្រាប់មិនទាន់ផ្ទុះ ឬអ្នកប្រើប្រាស់ដីធ្លី នឹងត្រូវបានត្រួតពិនិត្យជាប្រព័ន្ធផងដែរ។
ក្នុងអំឡុងពេលសាងសង់
អ្នកពាក់ព័ន្ធរបស់គម្រោងទាំងអស់នឹងអនុវត្តយ៉ាងតឹងរឹងនូវផែនការគ្រប់គ្រងបរិស្ថាន និងសង្គមដើម្បីធានាថា ហានិភ័យទាំងអស់ (កម្មករ និងសុវត្ថិភាពប្រជាជន ការការពារបរិស្ថាន និងបេតិកភណ្ឌវប្បធម៌ ឬការរំខាន (សំលេង ធូលី) សម្រាប់បរិស្ថាន និងសហគមន៍មូលដ្ឋាន នឹងត្រូវបានដោះស្រាយ និងវិធានការកាត់បន្ថយនឹងត្រូវបានអនុវត្ត។
នៅពេលបើកសេវាទារកដ្ឋានប្រចាំសហគមន៍នឹងត្រូវបានបំពាក់ដោយអាងប្រព្រឹត្តកម្មទឹកសំសំអុយដើម្បីប ញ្ចៀសការហូរទឹកកង្វក់ទៅក្នុងបរិស្ថាន។ ទីតាំង CBCC ក៏នឹងត្រូវបានជ្រើសរើសផងដែរដើម្បីចៀសវាងសំលេងរំខានផ្សេងៗ ដែលប៉ះពាល់ដល់សកម្មភាពកុមារ តាមដែលអាចធ្វើទៅបាន។
ដោយសារទំហំនៃទារកដ្ឋាននីមួយៗមានកម្រិត ផលប៉ះពាល់លើបរិស្ថាន និងសហគមន៍គួរតែត្រូវបានកំណត់។

## ពិគ្រោះយោបល់តាមសហគមន៍. តើអ្នកអាចចែករំលែកមតិរបស់អ្នកបានយ៉ាងដូច ម្តេច?

ការចូលរួមរបស់សហគមន៍គឺជាគន្លឹះសម្រាប់ភាពជោគជ័យនៃគម្រោង។ ក្រុមការងារគម្រោងបានធ្វើការពិគ្រោះយោបល់ជាច្រើនលើករួចមកហើយជាមួយអាជ្ញាធរជាតិ និង អាជ្ញាធរមូលដ្ឋាន និងក្រុមកម្មកររោងចក្រកាត់ដេរ និងក្រុមគ្រួសាររបស់ពួកគេ។

មុនពេលជ្រើសរើសទីតាំងណាមួយ ក្រុមការងារគម្រោងនឹងរៀបចំដំណើរការពិគ្រោះយោបល់នៅតាមសហគមន៍ដើម្បីបង្ហាញ គម្រោង រចនាប្លង់របស់ CBCC និងស្វាគមន៍រាល់មតិយោបល់ ឬកង្វល់នានា។ ដំណើរការនេះនឹងធ្វើឱ្យប្រាកដថាការរចនាប្លង់របស់ CBCC ត្រូវបានសម្របទៅនឹងស្ថានភាពជាក់លាក់នៃសហគមន៍ និងសមាជិករបស់សហគមន៍។ ក្នុងដំណាក់កាលសាងសង់ទាំងមូល ការកត់ត្រានឹងត្រូវបានធ្វើនៅសាលប្រជុំសាលាឃុំសម្រាប់អ្នកដែលចង់ចែករំលែកយោបល់អំពីផ្នែកណាមួយនៃគម្រោង។ វគ្គពិគ្រោះយោបល់នឹងត្រូវបានអនុវត្តបន្ត ហើយការចុះពិនិត្យមើលនៅនឹងកន្លែងសាងសងអាចត្រូវបានរៀបចំឡើងសម្រាប់សមាជិកសហគមន៍ នៅពេលត្រូវបានធានាថាមានសុវត្ថិភាពគ្រប់គ្រាន់។

នៅពេលដែលបានបើកដំណើរការពិគ្រោះយោបល់នឹងបន្ត។ គណៈកម្មាធិការប្រឹក្សា CBCC នឹងត្រូវបានបង្កើតឡើងសម្រាប់ CBCC នីមួយៗ ហើយនឹងមានការចូលរួមពីមេភូមិ គ្រូបង្រៀនសាលាមត្តេយ្យប្រសិនបើមាន ឪពុកម្តាយដែលជាប់ឆ្នោត/ស្ម័គ្រចិត្ត ប្រធានCBCC តំណាងគណៈកម្មការឃុំទទួលបន្ទុកការងារស្ត្រី និងកុមារ (CCWC) មន្ត្រីអប់រំ និងសុខភាពស្រុក និងតំណាងគណៈគ្រប់គ្រងរោងចក្រ។ បុគ្គលិកគម្រោង PE&D នឹងជួយដល់ការសម្របសម្រួលនៃកិច្ចប្រជុំផ្សេងៗ។ ក្រៅពីនេះក្នុងមួយឆ្នាំការប្រជុំសហគមន៍នឹងត្រូវរៀបចំឡើងដើម្បីធ្វើប័ណ្ណពិន្ទុសហគមន៍របស់ CBCC ដើម្បីវាយតម្លៃគុណភាពសេវាកម្ម។

## អំពី PE&D និងក្រុមធនាគារពិភពលោក

អង្គការ PE&D ជាអង្គការក្រៅរដ្ឋាភិបាលបារាំងដែលមានទំនាញ លើផ្នែកគាំពារ និងអភិវឌ្ឍន៍កុមារតូច។ PE&D ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៤ ជា“ អេស អូណអេស កុមារកម្ពុជា” ក្នុងគោលបំណងជួយកុមាររងគ្រោះដោយសារសង្គ្រាម។ ចាប់តាំងពីពេលនោះមកក្រុមការងាររបស់យើងបានប្រតិបត្តិការដើម្បីផ្តល់ការអភិវឌ្ឍកុមារតូច (០-៦ ឆ្នាំ) ការគាំទ្រដល់ក្រុមគ្រួសារនិងឪពុកម្តាយ ក៏ដូចជា សុខភាពមាតា និងទារក។ ធនាគារពិភពលោកគឺជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៤ ដើម្បីផ្តល់ប្រាក់កម្ចី ជំនួយ ការប្រឹក្សាគោលនយោបាយ និងការគាំទ្រផ្នែកបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍។ ធនាគារពិភពលោកគឺជាផ្នែកមួយនៃក្រុមធនាគារពិភពលោកដែលបានកំណត់គោលដៅពីរសម្រាប់ពិភពលោកឱ្យសម្រេចបាននៅឆ្នាំ ២០៣០៖

- បញ្ចប់ភាពក្រីក្រដោយបន្ថយភាគរយនៃប្រជាជនដែលរស់នៅក្រោមចំណូលតិចជាង ១.៩០ ដុល្លារ ក្នុងមួយថ្ងៃអោយមិនលើសពី ៣%
- លើកកម្ពស់វិបុលភាពរួមគ្នា ដោយជំរុញឱ្យមានកំណើនប្រាក់ចំណូលនៅក្នុងកំរិតទាប ៤០% សម្រាប់ប្រទេសទាំងអស់